**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ:......១៩៦ សហក / ក+គហ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

**សូមគោរពជូន**

- **ឯកឧត្តមរដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
- **ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍**
- **ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ÷** សេចក្តីជូនដំណឹងស្តីពីការចុះឈ្មោះចូលរួមការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧ (Cambodia ICT Awards 2017) របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**យោង÷** លិខិតលេខ ០៥៥២ បទ.វជបទបគព របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ កំពុងរៀបចំការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧ (Cambodia ICT Awards 2017)។ កម្មវិធីនេះ នឹងផ្តល់ជូនដល់ជ័យលាភីនូវ ពានរង្វាន់ប្រកបដោយកិត្យានុភាពសំដៅដល់ការទទួលស្គាល់ស្នាដៃផ្តើមរបស់ក្រសួង-ស្ថាប័ន ក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) សម្រាប់ដំណោះស្រាយនៅក្នុង

ការផ្ដល់សេវាសាធារណៈ ការផ្ដល់សេវា ឬដំណោះស្រាយដល់សង្គមឱ្យកាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ស្របតាមផែនការមេ និងគោលនយោបាយអភិវឌ្ឍន៍ ICT នៅកម្ពុជា។ម្យ៉ាងទៀតកម្មវិធីនេះ ក៏នឹងផ្ដល់រង្វាន់ដល់ជ័យលាភីលេខ១ ចំនួន មួយម៉ឺនដុល្លារអាមេរិក (10,000 USD) ជាមួយនឹងឱកាសផ្ទាល់ ដែលត្រូវបានជ្រើសរើសឱ្យក្លាយជាតំណាងរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឈានទៅចូលរួមពានរង្វាន់ ICT ថ្នាក់អាស៊ានឆ្នាំ២០១៧ (Asian ICT Awards 2017) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៅក្នុងខែវិច្ឆិកាខាងមុខនេះផងដែរ។

ការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧ វិញ្ញាសាវិស័យសាធារណៈ សំដៅលើកម្រងកម្មវិធីឧបករណ៍ ឬផលិតផលដែលអភិវឌ្ឍន៍ឡើង ក្នុងគោលបំណងផ្ដល់ប្រសិទ្ធិភាព កាត់បន្ថយពេលវេលា តម្លាភាព និងមានតម្លៃទាបសម្រាប់បម្រើសេវាសាធារណៈ។ ក្នុងន័យនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) សូមជម្រុញគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ ដែលមានកម្រងកម្មវិធីនានាពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យា ដូចជា កម្មវិធីគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) ជាដើម មេត្តាចុះឈ្មោះចូលរួមប្រកួតប្រជែងក្នុងកម្មវិធីខាងលើ ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ ***ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧*** កុំបីខាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាពិនិត្យលទ្ធភាពចុះឈ្មោះចូលរួម ដោយអនុគ្រោះ។

សូមឯកឧត្តម មេត្តាទទួលការគោរពរាប់អានពីខ្ញុំ។

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

**លេខទូរស័ព្ទទំនាក់ទំនង÷**

- លោក ស៊ុន ភពីជ អនុប្រធានវិទ្យាស្ថានជាតិ NIPTICT
  ០១៦ ៨៦៨ ៩៨៤

**ភ្ជាប់ជូន÷**

- ព័ត៌មានលម្អិតស្ដីពីការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ខុទ្ទកាល័យ ក.ស.ហ.វ.
លេខ: 12846584 ១៧
ថ្ងៃទី ២៣/០៥/១៧ ម៉ោង
អ្នកប្រគល់:

ការិយាល័យរដ្ឋបាល ក្រ.សហវ
មកដល់ថ្ងៃទី 23.05.17 ម៉ោង 10.30
លេខ: 1849C សហវ
អ្នកទទួល: ហត្ថលេខា
អ្នកប្រគល់: ហត្ថលេខា
បញ្ជូនទៅ:

លេខ: .............

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៧

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** សេចក្តីជូនដំណឹងស្តីពីការចុះឈ្មោះចូលរួមការប្រកួតប្រជែង ពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧ (Cambodia ICT Awards 2017) របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ភ្ជាប់ជូន:** ព័ត៌មានលម្អិតស្តីពី ការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ កំពុងរៀបចំការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧ (Cambodia ICT Awards 2017)។ កម្មវិធីនេះ នឹងផ្តល់ដល់ជ័យលាភីនូវ ពានរង្វាន់ប្រកបដោយកិត្យានុភាពសំដៅដល់ការទទួលស្គាល់ស្នាដៃផ្តួចផ្តើមរបស់ក្រសួង ស្ថាប័ន និងក្រុមហ៊ុន ក្នុងការប្រើប្រាស់ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) សម្រាប់ដំណោះស្រាយនៅក្នុងការផ្តល់សេវាសាធារណៈ ការផ្តល់សេវា ឬដំណោះស្រាយដល់សង្គមឲ្យកាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ស្របតាមផែនការមេ និងគោលនយោបាយជាតិអភិវឌ្ឍន៍ ICT នៅកម្ពុជា។ ម្យ៉ាងទៀត កម្មវិធីនេះ ក៏នឹងផ្តល់រង្វាន់ដល់ជ័យលាភីលេខ ១ ចំនួន **មួយម៉ឺនដុល្លារអាមេរិក (10,000USD)** ជាមួយនិងឱកាសផ្ទាល់ ដែលត្រូវបានជ្រើសរើសឲ្យក្លាយជាតំណាងរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឈានទៅចូលរួមកម្មវិធីពានរង្វាន់ ICT ថ្នាក់អាស៊ានឆ្នាំ២០១៧ (ASEAN ICT Awards 2017) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនៅក្នុងខែវិច្ឆិកាខាងមុខនេះផងដែរ។

ការប្រកួតប្រជែងពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧ វិញ្ញាសាវិស័យសាធារណៈ សំដៅលើកម្រងកម្មវិធីឧបករណ៍ ឬ ផលិតផលដែលអភិវឌ្ឍន៍ឡើង ក្នុងគោលបំណងផ្តល់ប្រសិទ្ធិភាព កាត់បន្ថយពេលវេលា តម្លាភាព និងមានតម្លៃទាបសម្រាប់បម្រើសេវាសាធារណៈ។ ហេតុដូចនេះ ខ្ញុំស្នើសុំ **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជម្រុញអង្គភាពក្រោមឱវាទ ដែលមានកម្រងកម្មវិធីនានា ដូចជា កម្មវិធីគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) ចុះឈ្មោះចូលរួមប្រកួតប្រជែង ពានរង្វាន់ ICT កម្ពុជា ឆ្នាំ២០១៧នេះ ចាប់ពី ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

*សូមទំនាក់ទំនង*
- លោក ស៊ុន រ៉ាពីដ
អនុប្រធានវិទ្យាស្ថានជាតិ NIPTICT
- 016 868 984
- rapid@niptict.edu.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

## ពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកម្ពុជា ឆ្នាំ២០១៧

Cambodia ICT Awards 2017

**សេចក្តីផ្តើម** (Introduction)

កម្មវិធីប្រកួតប្រជែង ពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកម្ពុជា ឆ្នាំ២០១៧ គឺជាកម្មវិធីប្រកួតប្រជែងថ្នាក់ជាតិមួយ ដែលបង្កើតឡើង ក្នុងគោលបំណងលើកតម្កើងនូវការយល់ដឹងខាងផ្នែកបច្ចេកវិទ្យាគមនាគន៍ និងព័ត៌មានក្នុងស្រទាប់សាធារណជន និងជួយកាត់បន្ថយគម្លាតឌីជីថល នៅក្នុងសហគមន៍ជំនួញ និងរវាងប្រជាជនដែលរស់នៅតាមបណ្តាខេត្ត និងក្នុងទីក្រុង។

កម្មវិធីប្រកួតប្រជែង ពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកម្ពុជា ២០១៧ នឹងផ្តល់ឱកាសក្នុងការជំរុញនវានុវត្តន៍ក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក៏ដូចជាលើកទឹកចិត្តបង្កើតគំនិតថ្មីៗ ក្នុងវិស័យក្នុងចំណោមក្រុមហ៊ុនឯកជន និងស្ថាប័នពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្មវិធីប្រកួតប្រជែង ពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកម្ពុជា ២០១៧ នឹងបង្ហាញនូវសមិទ្ធិផលជោគជ័យនានា ដែលសម្រេចបានពីការប្រកួតលើការធ្វើនវានុវត្តន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាមួយនឹងគំនិតច្នៃប្រឌិតថ្មីៗ ពីបណ្តាបេក្ខជនដែលបានដាក់ពាក្យចូលរួមប្រកួតប្រជែងដូចជា ក្រុមហ៊ុនឯកជន ក្នុងស្រុក និងអង្គភាពពាក់ព័ន្ធផ្សេងៗ ដែលជាកត្តារួមចំណែកក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅព្រះរាជាណាចក្រកម្ពុជា។

កម្មវិធីប្រកួតប្រជែងថ្នាក់ជាតិនេះក៏នឹងផ្តល់ឱកាសផ្ទាល់ដល់បេក្ខជន ក៏ដូចជាក្រុមហ៊ុនដែលទទួលបាន ជ័យលាភីពីកម្មវិធីនេះក្លាយជាតំណាងរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការចូលរួមប្រកួតប្រជែង ពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ថ្នាក់អាស៊ាន ឆ្នាំ២០១៧ (ASEAN ICT Awards 2017) ផងដែរ។

**ប្រភេទពានរង្វាន់** (Categories of Award)

- **វិស័យសាធារណៈ** (Public Sector)

សំដៅលើកម្រងកម្មវិធី ឧបករណ៍ ឬ ផលិតផលដែលអភិវឌ្ឍន៍ឡើង ក្នុងគោលបំណងផ្តល់ប្រសិទ្ធិភាព កាត់បន្ថយពេលវេលា តម្លាភាព និងមានតម្លៃទាបសម្រាប់បម្រើវិស័យសាធារណៈ ។ កម្មវិធីអាចត្រូវអភិវឌ្ឍដោយស្ថាប័នឯកជន ស្ថាប័នរដ្ឋ សហគ្រាសរដ្ឋដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល ឬជំនួយបរទេស និងអាចស្ថិតក្នុងដំណាក់កាលសាកល្បងនៅឡើយ។ កម្មវិធី មិនមានភាពចាំបាច់ត្រូវបានប្រើប្រាស់ពេញលេញនោះទេ ប៉ុន្តែត្រូវបានប្រើប្រាស់ដោយស្ថាប័នរដ្ឋណាមួយរួចហើយ។ កម្មវិធីដែលត្រូវបានអភិវឌ្ឍហើយត្រូវបានប្រើប្រាស់ដោយសហគ្រាសរដ្ឋ ឬស្ថាប័នរដ្ឋសម្រាប់គោលដៅរកប្រាក់ចំណេញ មិនរាប់បញ្ចូលក្នុងប្រភេទពានរង្វាន់នេះទេ។តំណាងរបស់ស្ថាប័នរដ្ឋដែលជ្រើសរើសដោយគណៈកម្មការ ត្រូវធ្វើបទបង្ហាញនានាបន្ទាប់ពីបានដាក់ពាក្យរួច។

- **វិស័យឯកជន** ( Private Sector )

សំដៅលើកម្រងកម្មវិធី ឧបករណ៍ ឬ ផលិតផលដែលសម្រាប់បម្រើសេចក្ដីត្រូវការរបស់វិស័យឯកជនរួមមានដូចជា កម្រងកម្មវិធី សម្រាប់គ្រប់គ្រងឧស្សាហកម្ម កម្រងកម្មវិធីសម្រាប់គ្រប់គ្រងភ័ស្ដុភារតាមអេឡិចត្រូនិក (e-Logistics) កម្រងកម្មវិធីសម្រាប់ការគ្រប់គ្រង ខ្សែសង្វាក់ផលិតកម្មជាដើម កម្រង កម្មវិធីឧស្សាហកម្មហិរញ្ញវត្ថុ ទំនាក់ទំនង សេវាសុខាភិបាលតាមអេឡិចត្រូនិក ទេសចរ និងបដិសណ្ឋាកិច្ចជាដើម។ល។ ក្រុមហ៊ុនចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមានម្ចាស់ភាគហ៊ុនក្នុងស្រុក ១០០%។ សម្រាប់ក្រុមហ៊ុន សហកម្មសិទ្ធិរវាងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស ម្ចាស់ភាគហ៊ុនក្នុងស្រុកត្រូវមានភាគហ៊ុនយ៉ាងតិច ៥១%។

- **ការរួមចំណែកទទួលខុសត្រូវក្នុងសង្គម** ( Corporate Social Responsibility )

សំដៅលើកម្រងកម្មវិធី ឧបករណ៍ ឬផលិតផលដែលអភិវឌ្ឍឡើង សម្រាប់គាំទ្រសហគមន៍របស់ខ្លួន ក្នុងគោលបំណងលើកកម្ពស់គុណភាពជីវិត និងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស ក្នុងគោលបំណងជួយកាត់បន្ថយគម្លាតឌីជីថល។

- **មាតិកាឌីជីថល** ( Digital Content )

សំដៅលើកម្រងកម្មវិធី ឧបករណ៍ ឬ ផលិតផលដែលអភិវឌ្ឍន៍ឡើងសម្រាប់ផ្ដល់នូវការគ្រប់គ្រងនិងគាំទ្របច្ចេកទេសទៅដល់ព័ត៌មាន និងឧស្សាហកម្មកំសាន្ត ដូចជា ការផ្សាយទូរទស្សន៍ វិទ្យុ រោងភាពយន្ត តន្ត្រី ទស្សនាវដ្ដី កាសែត ព័ត៌មានលើអ៊ីនធឺណែត ហ្គេមកំសាន្ត។ ផលិតផលនោះអាចបង្កើតឡើង ជា ទម្រង់អត្ថបទ សំឡេង រូបភាព និងវីដេអូជាដើម។

- **ការបង្កើតធុរកិច្ច** ( Start-up Company )

សំដៅលើកម្រងកម្មវិធី ឧបករណ៍ ឬ ផលិតផលដែលអភិវឌ្ឍន៍ឡើងដោយក្រុមហ៊ុនធុរកិច្ច បង្កើតតិចជាងរយៈពេល៣ឆ្នាំ ពីកាលបរិច្ឆេទចុះឈ្មោះដាក់ពាក្យប្រកួតប្រជែង។ ម្ចាស់ភាគហ៊ុនធំត្រូវតែជាអ្នកដែលរកឃើញ ឬជាអ្នកផ្ដួចផ្ដើមគំនិតមុនដំបូង និងមិនមែនជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមេណាមួយ។

- **ការស្រាវជ្រាវ និងការអភិវឌ្ឍន៍** ( Research and Development )

សំដៅលើកម្រងកម្មវិធី ឧបករណ៍ ឬ ផលិតផលដែលទើបតែស្រាវជ្រាវ រកឃើញចេញពីគំនិតថ្មី សម្រាប់បម្រើតម្រូវការទីផ្សារ ចេញពីសាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ ឬក្រុមហ៊ុនដែលរកឃើញ និងបង្កើតគំនិតថ្មីៗ។

កម្មវិធីមិនទាន់ប្រើប្រាស់នៅឡើយ ហើយមិនទាន់បានបញ្ចប់រួចរាល់សព្វគ្រប់ ប៉ុន្តែអាចធ្វើបង្ហាញពីមុខងារ និងដំណើការរបស់វា ព្រមទាំងរក្សាកម្មសិទ្ធិបញ្ញាជាម្ចាស់របស់អ្នកដែលរកឃើញ ឬជាអ្នកផ្ដួចផ្ដើមគំនិតមុនដំបូង (ផ្ទាល់ខ្លួន ឬក្រុមហ៊ុន ដោយប្រើប្រាស់ប្រភពថវិកាផ្ទាល់ខ្លួន ឬពីអតិថិជន/ អ្នកប្រើប្រាស់។

**កាលវិភាគ** ( Schedule )

| ល.រ | ការពិពណ៌នា | កាលបរិច្ឆេទ |
|---|---|---|
| ១ | ពិធីប្រកាសបើកការប្រកួតប្រជែងពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងពត៌មានកម្ពុជា ឆ្នាំ២០១៧ | ១៥ កុម្ភៈ ២០១៧ |
| ២ | ចាប់ផ្ដើមទទួលពាក្យប្រកួតប្រជែង | ១៥ កុម្ភៈ ២០១៧ |

| | | |
|---|---|---|
| ៣ | កាលបរិច្ឆេទឈប់ទទួលពាក្យប្រកួតប្រជែង | ៣០ ឧសភា ២០១៧ |
| ៤ | ប្រកាសលទ្ធផលជ្រើសរើសវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ | ១៥ មិថុនា ២០១៧ |
| ៥ | ជ្រើសរើសវគ្គផ្តាច់ព្រ័ត្រ | ដើមខែកក្កដា ២០១៧ |
| ៦ | ពិធីប្រគល់ពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន ឆ្នាំ២០១៧ | ដើមខែកក្កដា ២០១៧ |
| ៧ | បញ្ជូនម្ចាស់ជ័យលាភីទៅប្រកួតថ្នាក់តំបន់ (អាស៊ាន) | ដើមខែកក្កដា ២០១៧ |

**ពានរង្វាន់** ( Prizes Award )

ម្ចាស់ជ័យលាភីនៅក្នុងកម្មវិធីប្រកួតប្រជែងនេះ នឹងទទួលបានពានរង្វាន់ រួមមាន វិញ្ញាបនប័ត្រជ័យលាភី ពានជ័យ និងរង្វាន់ជាសាច់ប្រាក់ យោងទៅតាមលំដាប់ថ្នាក់នៃជ័យលាភីនីមួយៗដូចខាងក្រោមៈ

- ជ័យលាភីទី ១ នឹងទទួលបានទឹកប្រាក់ ១០.០០០ ដុល្លា
- ជ័យលាភីទី ២ នឹងទទួលបានទឹកប្រាក់ ៣.០០០ ដុល្លា
- ជ័យលាភីទី ៣ នឹងទទួលបានទឹកប្រាក់ ១.០០០ ដុល្លា

ជ័យលាភីទៅតាមប្រភេទវិញ្ញាសារនីមួយៗ នឹងទទួលបានរង្វាន់លួងចិត្ត និង វិញ្ញាបនប័ត្រជ័យលាភី។

**លក្ខខណ្ឌនៃការចូលរួមប្រកួត** ( Eiligibility )

i. ក្រុមហ៊ុន ដែលមានបំណងចង់ចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះ ត្រូវតែជាក្រុមហ៊ុនចុះបញ្ជីនិងមានអាជ្ញាប័ណ្ណជំនួញត្រឹមត្រូវ ស្របទៅតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា។

ii. បេក្ខជនដែលមានបំណងចង់ចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះ ត្រូវមានសញ្ជាតិខ្មែរ ឬមានលំនៅដ្ឋានអចិន្ត្រៃយ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះបេក្ខជនដែលមិនមានសញ្ជាតិខ្មែរ ឬ មិនមានលំនៅដ្ឋានអចិន្ត្រៃយ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងចង់ចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះ គឺ តម្រូវឱ្យបេក្ខជននោះមានលិខិតបញ្ជាក់ច្បាស់លាស់ពីក្រុមហ៊ុនក្នុងស្រុក ទើបអាចមានសិទ្ធិចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះបាន។

iii. ក្រុមហ៊ុនដែលក្ស័យធន មិនត្រូវបានអនុញ្ញាតអោយចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះបានឡើយ។

iv. ផលិតផលដែលដាក់ប្រកួតប្រជែងក្នុងកម្មវិធីនេះ ត្រូវតែជាផលិតផលរក្សាកម្មសិទ្ធិបញ្ញាដោយក្រុមហ៊ុនសាមីផ្ទាល់ និងអភិវឌ្ឍន៍ ឬបង្កើតឡើងដោយប្រើប្រាស់ធនធានយ៉ាងហោចណាស់៥១% នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ការតែងតាំងចៅក្រម** ( Appiontment of the Judges )

i. សមាជិកចៅក្រមត្រូវបានតែងតាំងចេញពីតំណាងស្ថាប័នរដ្ឋ វិស័យឯកជន គ្រឹះស្ថានអប់រំ និងសង្គមស៊ីវិល ដែលមានចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន យ៉ាងតិច ៥ឆ្នាំ។

ii. ភារកិច្ចរបស់ចៅក្រម គឺមានសិទ្ធសម្រេចជ្រើសរើសជ័យលាភីក្នុងការប្រកួតប្រជែង ដោយគោរពទៅតាមល័ក្ខខ័ណ្ឌនៃការប្រកួតប្រជែងពានរង្វាន់ថ្នាក់ជាតិនេះ។
iii. ដំណើរការវិនិច្ឆ័យនេះ នឹងត្រូវធ្វើបទបង្ហាញចំពោះមុខចៅក្រមសម្រាប់វគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧ និងវគ្គផ្ដាច់ព្រ័ត្រថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧។
iv. គណៈកម្មាធិការមិនអនុញ្ញាតឲ្យមានការប្រកួតប្រជែងលើស្នាដៃ/ផលិតផលដែលមានលក្ខណៈដូចគ្នាឡើយ។
v. ការសម្រេចជ្រើសរើសជ័យលាភីនីមួយៗ នឹងត្រូវផ្អែកលើលទ្ធផលវាយតំលៃសរុប ដោយក្រុមចៅក្រម។
vi. លទ្ធផលចុងក្រោយនៃការប្រកួតនេះ នឹងត្រូវរក្សាជាសម្ងាត់ និងប្រកាសនៅក្នុងព្រឹត្តិការណ៍ប្រគល់ពានរង្វាន់តែប៉ុណ្ណោះ។

**លក្ខណៈវិនិច្ឆ័យ** ( Judging Criteria )

បេក្ខជន/ ក្រុមហ៊ុនដែលបានដាក់ពាក្យចូលរួមប្រកួតប្រជែង នឹងត្រូវទទួលការវាយតំលៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ០៥យ៉ាងដូចតទៅ៖

i. ភាពមានតែមួយគត់
ii. កស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីទស្សនៈទាន សក្ដានុពលទីផ្សារ ឬប្រសិទ្ធភាពនៃការប្រើប្រាស់ផលិតផល
iii. លក្ខណៈសម្បត្តិរបស់ផលិតផល
iv. ការប្រើប្រាស់បច្ចេកវិទ្យា
v. ការធ្វើបទបង្ហាញ

**ការចូលរួមប្រកួតប្រជែង** ( How to apply )

សំណុំបែបបទចូលរួមកម្មវិធីប្រកួតប្រជែងនេះអាចទាញយកពីគេហទំព័រ **www.cambodiaictaward.com** ដោយផ្ទាល់ រួចបំពេញពាក្យចុះឈ្មោះតាមរយៈទម្រង់ពាក្យអេឡិចត្រូនិក បន្ទាប់មកផ្ញើ URL វីដេអូនៅលើ Youtube មុននឹងចុចប៊ូតុង Submit។

បេក្ខជន/ក្រុមហ៊ុន ត្រូវដាក់សំណុំបែបបទចូលរួមកម្មវិធីប្រកួតប្រជែង និងឯកសារពាក់ព័ន្ធដទៃទៀត ក្នុងស្រោមសំបុត្របិទជិតដោយដៃ ជាមួយត្រាបញ្ជាក់ក្រុមហ៊ុនរបស់សាមីខ្លួន ហើយផ្ញើរទៅកាន់អាស័យដ្ឋាន ខាងលើ ឬអ៊ីម៉ែលមកអាស័យដ្ឋាន **cicta@niptict.edu.kh** ។

**ទំនាក់ទំនងព័ត៌មានបន្ថែម** ( More Information )

សម្រាប់ព័ត៌មានលំអិតផ្សេងៗដែលទាក់ទងទៅនឹងការប្រកួតប្រជែងពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជា២០១៧ បេក្ខជន/ក្រុមហ៊ុនអាចធ្វើការទាក់ទងតាមរយៈទូរស័ព្ទរឺផ្ញើអ៊ីម៉ែលមកកាន់អាស័យដ្ឋានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| អ្នកទំនាក់ទំនង | : | លោក ស៊ុន វ៉ាពីជ | កញ្ញា យ៉ង់ ម៉ារីយ៉ា |
| ទូរស័ព្ទលេខ | : | ០១៦ ៨៦៨៩៨៤ | ០១៧ ៨៨២៨៣៨ |
| អ៊ីម៉ែល | : | cicta@niptict.edu.kh | cicta@niptict.edu.kh |